# ការពារទារករបស់អ្នក សំរាប់ការរស់នៅ

ពេលដែលស្ត្រីមានផ្ទៃពោះមានជំងឺថ្លើមប្រភេទ B



## ហេតុអ្វីស្ត្រីមានផ្ទៃពោះយកចិត្តទុកដាក់ពីជំងឺថ្លើមប្រភេទ B?

ជំងឺថ្លើមប្រភេទ B គឺជាជំងឺថ្លើមកម្រិតធ្ងន់មួយ ដែលអាចត្រូវចម្លងទៅកាន់អ្នកដទៃទៀតបានយ៉ាងងាយ ។ ជាការសំខាន់ណាស់សំរាប់ស្ត្រី ដើម្បីរកឱ្យឃើញថា ខ្លួនគាត់មានជំងឺថ្លើមប្រភេទ B ដែរឬទេ, បើមានគាត់អាចទទួលការរក្សាព្យាបាលរោគនេះបាន ។ វាអាចកើតមានដែរ ចំពោះស្ត្រីមានផ្ទៃពោះដែលមានជំងឺថ្លើមប្រភេទ B ចម្លងមេរោគដល់ទារករបស់នាងនៅពេលផ្តល់ឆ្លងទន្លេ ។ ជាភ័ព្វល្អ មានថ្នាំបង្ការការពារទារកទាំងឡាយកុំឱ្យឆ្លងជំងឺថ្លើមប្រភេទ B ។

## តើជំងឺថ្លើមប្រភេទ B គឺជាអ្វី?

"ជំងឺថ្លើម" មានន័យថា ជាការរលាកថ្លើម ។ ជំងឺថ្លើមប្រភេទ B គឺជាជំងឺថ្លើមម្យ៉ាង ដែលអាចឆ្លងដែលកើតចេញមកពីការឆ្លងមេរោគរបស់ជំងឺថ្លើមប្រភេទ B ។ នៅពេលដែលមនុស្សម្នាក់ឆ្លងជំងឺមេរោគជំងឺថ្លើមប្រភេទ B នេះអាចរស់នៅក្នុងរាងកាយរបស់អ្នកជំងឺនេះអស់មួយជីវិតរបស់គាត់ ហើយបណ្តាលឱ្យមានបញ្ហាថ្លើមធ្ងន់ធ្ងរ ។

## តើជំងឺថ្លើមប្រភេទ B អាចត្រូវបានឆ្លងរាលដាលទៅដល់ទារកឬទេ?

អាច ។ មេរោគជំងឺថ្លើមប្រភេទ B អាចឆ្លងរាលដាលទៅដល់ទារកក្នុងកំឡុងពេលឆ្លងទន្លេសម្រាលកូន ។ ការឆ្លងនេះអាចកើតឡើងក្នុងកំឡុងពេលការឆ្លងទន្លេសម្រាលកូនតាមរន្ធយោនី ឬ តាមរយៈការវះកាត់ ។

## តើជំងឺថ្លើមប្រភេទ B ឆ្លងរាលដាលតាមរបៀបណាផ្សេងទៀតទេ?

ជំងឺថ្លើមប្រភេទ B ក៏អាចត្រូវបានឆ្លងរាលដាលនៅពេលដែលឈាម ទឹកកាម ឬវត្ថុរាវផ្សេងទៀតនៃរាងកាយចេញពីបុគ្គលដែលមានមេរោគ ចូលទៅក្នុងរាងកាយនៃជនណាម្នាក់ដែលមិនទាន់ឆ្លង ។ មេរោគនេះគឺងាយឆ្លងណាស់ ហើយត្រូវបានចម្លងយ៉ាងងាយតាមរយៈការដាច់រហែកស្បែក ឬជាលិកាទន់ៗដូចជាច្រមុះមាត់ និង ភ្នែក ជាដើម ។

ការឆ្លងនេះ អាចកើតមានតាមរយៈការប៉ះពាល់ផ្ទាល់ជាមួយឈាមចេញមកពីបុគ្គលដែលមានជំងឺ សូម្បីតែនៅក្នុងបរិមាណបន្តិចបន្តួចរហូតដល់តូចពេកមើលមិនឃើញ ។ ជំងឺថ្លើមប្រភេទ B ក៏អាចឆ្លងរាលដាលតាមរយៈការរួមភេទជាមួយបុគ្គលដែលមានជំងឺនេះផងដែរ ។

**CDC ឱ្យយោបល់ថា ទារកទាំងឡាយទទួលការចាក់ថ្នាំ HBIG និង ដូសថ្នាំដំបូងចាក់បង្ការជំងឺថ្លើមប្រភេទ B ក្នុងកំឡុងពេល 12 ម៉ោងនៃការចាប់កំណើត។**

## តើជំងឺថ្លើមប្រភេទ B ធ្ងន់ធ្ងរកម្រិតណា?

នៅពេលដែលទារកទាំងឡាយឆ្លងជំងឺថ្លើមប្រភេទ B ពួកគេមានឱកាស 90% ក្នុងការឆ្លងរ៉ាំរ៉ៃពេញមួយជីវិត ។ មនុស្សរហូតដល់ 1 ក្នុងចំណោម 4 នាក់ដែលមានជំងឺថ្លើមប្រភេទ B រ៉ាំរ៉ៃ មានបញ្ហាសុខភាពធ្ងន់ធ្ងរ ។ ជំងឺថ្លើមប្រភេទ B អាចបណ្តាលឱ្យខូចថ្លើម ឈឺថ្លើម និង មហារីកថ្លើម ។

## តើជំងឺថ្លើមប្រភេទ B មានលក្ខណៈទូទៅយ៉ាងដូចម្តេចដែរ?

ប្រជាជនប្រមាណ 350 លាន នាក់ទូទាំងពិភពលោក និង 1.2 លាននាក់នៅសហរដ្ឋអាមេរិក ត្រូវបានឆ្លង ជំងឺថ្លើមប្រភេទ B ។



## តើវេជ្ជបណ្ឌិតអាចការពារទារកពីការឆ្លងជំងឺថ្លើមប្រភេទ B ដែរឬទេ?

អាច ។ ទារកចាប់កំណើតទៅនឹងស្ត្រីដែលមានជំងឺថ្លើមប្រភេទ B ទទួលបានការចាក់ថ្នាំពីរដងភ្លាមៗក្រោយពេលកើត ។ មួយដូសដំបូង គឺជាថ្នាំបង្ការជំងឺថ្លើមប្រភេទ B និងចាក់មួយដូសផ្សេងទៀតឈ្មោះថា HBIG ។ ការចាក់ថ្នាំទាំងពីរ ជួយការពារទារកពីការឆ្លងជំងឺថ្លើម ប្រភេទ B ។ ការចាក់ថ្នាំទាំងនេះ មានដំណើរការប្រសើរបំផុត នៅពេលដែលទារកទាំងនោះ ត្រូវបានគេផ្តល់ឱ្យនៅក្នុងកំឡុងពេល 12 ម៉ោងក្រោយកើត ។

## តើ HBIG គឺជាអ្វី?

HBIG គឺជាថ្នាំម្យ៉ាង ដែលផ្តល់ទៅឱ្យរាងកាយរបស់ទារកនូវ "ការបង្កើនកម្លាំង" ឬ ជំនួយបន្ថែមដើម្បីប្រឆាំងមេរោគឱ្យបានឆាប់ នៅពេលដែលទារក កើតមកភ្លាម ។ ការចាក់ថ្នាំ HBIG សម្រាប់តែទារកទាំងឡាយណា ដែលមានមាតាទាំងឡាយរបស់ពួកគេ មានជំងឺថ្លើមប្រភេទ B ប៉ុណ្ណោះ ។



## តើធ្វើយ៉ាងណាអាចឱ្យខ្ញុំដឹងច្បាស់ថា គ្រួសាររបស់ខ្ញុំត្រូវបានទទួលការការពារពីជំងឺថ្លើមប្រភេទ B ?

### នាំអ្នកទាំងអស់គ្នាទៅធ្វើតេស្ត៍ រកជំងឺថ្លើមប្រភេទ B

ឪពុកទារករបស់អ្នក និងអ្នកគ្រប់គ្នាផ្សេងទៀត ដែលរស់នៅក្នុងផ្ទះរបស់អ្នក គួរទៅជួបវេជ្ជបណ្ឌិត ឬមន្ទីរព្យាបាលឱ្យគេធ្វើតេស្ត៍ឈាម ។ ការធ្វើតេស្ត៍ឈាមសមាជិកគ្រួសាររបស់អ្នក ជួយប្រាប់ថា តើពួកគេមានជំងឺថ្លើមប្រភេទ B នេះដែរឬទេ ។ បើសិនជាពួកគេមិនមានជំងឺថ្លើមប្រភេទ B ទេនោះ វេជ្ជបណ្ឌិតនឹងប្រាប់ពួកគេអំពីការចាក់ថ្នាំបង្ការជំងឺថ្លើមប្រភេទ B ដើម្បីការពារពួកគេពីការឆ្លងមេរោគនេះ ។

### គ្របកន្លែងមុត និងកន្លែងឈឺ

ចាប់តាំងពីជំងឺថ្លើមប្រភេទ B ចម្លងរាលដាលតាមរយៈឈាមនោះ អ្នកដែលមានជំងឺថ្លើមប្រភេទ B គួរតែប្រយ័ត្ន កុំឱ្យអ្វីៗដល់អ្នកផ្សេងទៀត ដែលអាចមានជាប់ឈាមរបស់ខ្លួននៅលើ វត្ថុទាំងនោះឡើយ ។ វាមានសារៈសំខាន់ណាស់ ដែលមិនចែករំលែករបស់ប្រើប្រាស់ផ្ទាល់ខ្លួនដូចជា កាំបិតកោរ កន្ត្រៃកាត់ក្រចក ច្រាស់ដុសធ្មេញ ឬឧបករណ៍ត្រួតពិនិត្យជាតិស្ករ ។ កន្លែងមុត និងកន្លែងឈឺ គប្បី គ្របដណ្តប់ការពារនៅខណៈពេលដែលកន្លែងទាំងនេះកំពុងធ្វើការជាសះស្បើយ ។

### កុំទំពារអាហារឱ្យទារករបស់អ្នក

បរិមាណឈាមតិចតួច ពេលខ្លះអាចមាននៅក្នុងមាត់របស់មនុស្សម្នាក់ ។ កុំទំពារអាហារ បញ្ចុកទារករបស់អ្នកឱ្យសោះ ។

## តើទារករបស់ខ្ញុំត្រូវការការចាក់ថ្នាំជំងឺថ្លើមប្រភេទ B ប៉ុន្មានដង?

ទារករបស់អ្នកនឹងទទួលបានការចាក់ថ្នាំ 3 ឬ 4 ដង ដោយផ្អែកទៅលើម៉ាកថ្នាំបង្ការណាមួយដែលត្រូវបានប្រើប្រាស់ ។ ក្រោយពីដូសថ្នាំបង្ការដំបូងត្រូវបានផ្តល់ឱ្យនៅមន្ទីរពេទ្យនោះ ដូសថ្នាំបង្ការបន្ទាប់ ត្រូវផ្តល់ឱ្យបន្ទាប់ពីអាយុ 1-2 ខែ ។ ជាធម្មតា ដូសថ្នាំបង្ការចុងក្រោយ គឺត្រូវ ផ្តល់ឱ្យនៅពេលដែលទារករបស់អ្នកមានអាយុមួយឆ្នាំ ។ សូមសាកសួរវេជ្ជបណ្ឌិត ឬ គិលានុបដ្ឋាយិការបស់អ្នក ពីពេលវេលាដែលទារករបស់អ្នកត្រូវត្រឡប់មកចាក់ថ្នាំវិញ មួយលើកៗ ។

## តើទារករបស់ខ្ញុំត្រូវការចាក់ថ្នាំបង្ការទាំងអស់នេះឬ?

គ្រប់ការចាក់ថ្នាំការពារជំងឺថ្លើមប្រភេទ B មានភាពចាំបាច់ ដើម្បីជួយរក្សារទារករបស់អ្នកពីការឆ្លងជំងឺថ្លើមប្រភេទ B ។

**ការពារពីជំងឺថ្លើមប្រភេទ B ។**
**ត្រូវយកទារករបស់អ្នកចាក់ថ្នាំបង្ការ ។**

## តើធ្វើយ៉ាងដូចម្តេច ទើបខ្ញុំដឹងថា ទារករបស់ខ្ញុំត្រូវបានការការពារ?

បន្ទាប់ពីទទួលបានការចាក់ថ្នាំការពារជំងឺថ្លើមប្រភេទ B ទាំងអស់នេះមក វេជ្ជបណ្ឌិតរបស់អ្នកនឹងធ្វើតេស្ត៍ឈាមទារករបស់អ្នក ។ ការធ្វើតេស្ត៍ឈាមបង្ហាញឱ្យអ្នក និងវេជ្ជបណ្ឌិតរបស់អ្នកដឹងថា ទារករបស់អ្នកត្រូវបានការពារ ហើយមិនមានជំងឺថ្លើមប្រភេទ B ទេ ។ ជាធម្មតា ការធ្វើតេស្ត៍ឈាម ត្រូវគេធ្វើចប់រួចរាល់រៀង រាល់ 1-2 ខែម្តង បន្ទាប់ពីការចាក់ថ្នាំចុងក្រោយមក ។ ចូរដឹងឱ្យច្បាស់ថា អ្នកត្រូវនាំទារករបស់អ្នកត្រឡប់មកជួបវេជ្ជបណ្ឌិតរបស់អ្នកវិញ ដើម្បីធ្វើតេស្ត៍ឈាមដ៏មានសារៈសំខាន់នេះ ។

## ជំងឺថ្លើមប្រភេទ B មិនចម្លងរាលដាលតាមរយៈ



### ការបំបៅដោយទឹកដោះម្តាយ

វាមានសុវត្ថិភាពសំរាប់អ្នកបំបៅទារករបស់អ្នក ។ អ្នកមិនអាចចម្លងជំងឺថ្លើមប្រភេទ B ដល់ទារករបស់អ្នក ដោយសារទឹកដោះរបស់អ្នកនោះទេ ។

### ការចំអិនអាហារ និងការញុំាអាហារ

វាមានសុវត្ថិភាពសំរាប់អ្នក ដើម្បីរៀបចំ និងញុំាអាហារជាមួយគ្រួសាររបស់អ្នក ។ ជំងឺថ្លើមប្រភេទ B មិនត្រូវបានចម្លងតាមរយៈចានអាហារ ការចំអិន ឬរបស់របរចង្ក្រានបាយរួមសំរាប់ញុំាអាហារ ឬ កែវផឹកទឹករួមគ្នាឡើយ ។

### ការអោប និងការថើបជំពិត

អ្នកអាចអោប និង ថើបជំពិតទារក, សមាជិកគ្រួសាររបស់អ្នក ឬ អ្នកដទៃទៀតដែលជិតស្និទ្ធ នឹងអ្នកបាន ។ អ្នកមិនអាចចម្លងដល់នរណាម្នាក់នូវជំងឺថ្លើមប្រភេទ B ដោយសារការអោប និង ថើបជំពិតពួកគេឡើយ ។ ជំងឺថ្លើមប្រភេទ B ក៏មិនឆ្លងរាលដាលតាមរយៈការកណ្តាស់ ឬ ការក្អកដែរ ។

## សំរាប់ព័ត៌មានបន្ថែម

ចូរនិយាយនឹងអ្នកជំនាញការផ្នែកសុខភាពរបស់អ្នក ដោយហៅទូរស័ព្ទទៅក្រសួងសុខាភិបាលរបស់អ្នក ឬ ចូរមើល គេហទំព័រ www.cdc.gov/hepatitis*

* **ឯកសារជាភាសាខ្មែរអាចទទួលបានមានកំណត់។**


DEPARTMENT OF HEALTH & HUMAN SERVICES
Centers for Disease Control and Prevention
*Division of Viral Hepatitis*

www.cdc.gov/hepatitis

Publication No. 22-0439

July 2010